# រឿងព្រះមហោសថ

១

Roeung Preah Mohoosoth
B-3
D-24
N-2927
INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL



ARCHIVES NATIONALES
ARCHIVES NATIONALES DOTE
361-5970

# រឿង

# ព្រះមហោសថ

ព្រះមហា គង់កេត ព្រះមហា បិនយ៉ាន

វត្តបទុមគង្គា ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល

ចំឡងតាមច្បាប់បុរាណបាន

24-16-88
1956

ការផ្សាយរបស់

លេខ ៨៨ វិថីអែមេក្រង់ ភ្នំពេញ
ជិតរោងកុនព្រហ្មបាយ័នផ្ទាល់

រក្សាសិទ្ធិ

ព. ស. ២៤៩៥ គ. ស. ១៩៥៦

# អារម្ភកថា

បុព្វហេតុដែលនាំឲ្យកើតសៀវភៅនេះឡើង ដោយសាថៅកែ គិម-គី បានមកនិយាយឲ្យខ្ញុំរករឿងនេះ ដើម្បីនឹងយកទៅបោះពុម្ពផ្សាយ ខ្ញុំក៏មានចិត្តត្រេកអរដោយនឹកថា: រឿងនេះ ជារឿងសម្រាប់បំភ្លឺប្រាជ្ញាឲ្យដឹងច្បាស់ ព្រោះមានប្រស្នាគួរឆ្ងល់ជាច្រើន ហេតុនេះហើយ ខ្ញុំក៏រកក្បួនមកចម្លងជូនទៅគាត់តាមបំណង ។

ដោយអំណាចសេចក្ដីព្យាយាមនេះ សូមឲ្យប្រជាជនក្នុងត្រៃលោក បានសេចក្ដីសុខ នឹងសូមឲ្យអក្សរសាស្ត្រខ្មែរផ្សាយទៅក្នុងប្រទេសឲ្យបានគ្រប់គ្រាន់បរិបូណ៌ ។

ម្យ៉ាងទៀត ខ្ញុំសូមអភ័យទោសអំពីសំណាក់ លោកអ្នកប្រាជ្ញទាំងឡាយ ក្រែងមានខ្វះខាតឬភ្លាំងភ្លាត់កន្លែងណា សូមជួយកែដម្រង់ផង សូមអរគុណទុកជាមុន ។

ថ្ងៃទី ១៣ ខែតុលា ព.ស. ២៤៩៥ គ.ស. ១៩៥២

ព្រះមហា គង់-កេត ព្រះមហា បិន-យ៉ាន

វត្តបទុមគង្គា ឃុំបាក់ខែង ស្រុកមុខកំពូលខេត្តកណ្ដាល

# រឿង

# ព្រះមហោសថ

បញ្ញាហោ សព្វសេយាតិ ឥមំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ បញ្ញាបារមឹ អារព្ភ កថេសិ ។

*កាលព្រះសាស្តាបរមគ្រូជាម្ចាស់ ទ្រង់គង់ក្នុងវត្តជេតពន ទ្រង់សំដែងធម៌ប្រារព្ធនូវបញ្ញាបារមីថា* បញ្ញាហោ *សព្វសេនាយ ដូច្នេះជាដើម ។*

*សេចក្តីថា: ម្នាលភិក្ខុទាំងឡាយ ក្នុងកាលកន្លងទៅហើយមាន ស្តេចមួយព្រះអង្គព្រះនាមវិទេហរាជ សោយរាជ្យនៅនគរមិថិលា ។ ព្រះអង្គមានអាចារ្យ ៤ នាក់ ជាអ្នកទូន្មានប្រៀនប្រដៅមើលហេតុការផ្សេងៗ ១ ឈ្មោះអាចារ្យ សេនក, ២ ឈ្មោះអាចារ្យ កមិន, ៣ ឈ្មោះអាចារ្យទេវិន្ទ, ៤ ឈ្មោះអាចារ្យ បកុ; អាចារ្យទាំង ៤ នាក់នេះ ជាអ្នកមានប្រាជ្ញាចេះដឹងស្មើគ្នា ។*

*រាត្រីមួយ ព្រះរាជាទ្រង់ផ្ទុំលើគ្រឡាព្រះបន្ទំ លុះពេលទៀបភ្លឺ ទ្រង់សុបិននិមិត្តឃើញហាក់ដូច ភ្នក់ភ្លើងធំ៤ឆេះឡើងស្មើបន្ទាយ ហើយ មានភ្នក់ភ្លើងមួយទៀតតូចប៉ុនអំពិលអំពែក មានរស្មីភ្លឺរុងរឿងជាងភ្នក់ភ្លើងទាំង ៤ នោះទៅទៀត ផុសឡើងចំពាក់កណ្តាល ភ្នក់ភ្លើងតាំង ៤ នោះ មានពន្លឺផ្សាយទៅដល់ទ្វីបទាំង ៤ រហូតដល់ព្រហ្មលោក ។ មនុស្សទាំងឡាយ កាន់គ្រឿងសក្ការទៅបូជា ដើរជាន់លើគំនររងើក*

ភ្លើងនោះ ឥតមានរលាកសោះឡើយ, លុះទ្រង់តើនចាកក្រឡាព្រះបន្ទំ ហើយ ទ្រង់ត្រាស់សួរអាចារ្យទាំង ៤ នាក់ឲ្យគាត់សុបិននិមិត្តនោះ ថ្វាយ ៗ អាចារ្យទាំង៤ ក្រាបទូលថាបពិត្រព្រះសម្មតិទេព ភ្នក់ភ្លើង ទាំង ៤ នោះគឺៈ ខ្ញុំទូលព្រះបង្គំជាអ្នកប្រាជ្ញសម្រាប់ព្រះអង្គសព្វថ្ងៃនេះ; ឯភ្នក់ភ្លើង ១ តូចតែមានរស្មីអស្ចារ្យនោះ គឺមានអ្នកប្រាជ្ញ ១ កើតឡើង សម្រាប់ព្រះអង្គទៀតហើយ ជាអ្នកមានប្រាជ្ញាណាស់ ល្បីទូទៅក្នុង ទ្វីបទាំង ៤ រហូតដល់ទេវតា បញ្ញាគ្របសង្កត់លើទូលព្រះបង្គំទាំង ៤ នាក់ នេះទៅទៀត សូមទ្រង់ជ្រាប ៗ

កាលនោះព្រះបរមពោធិសត្វ ជាទេវបុត្រ ទ្រង់ច្យុតមកចាប់ បដិសន្ធិក្នុងផ្ទៃនៃនាងសុមនាទេវី ជាភរិយារបស់សិរីវឌ្ឍសេដ្ឋី នៅទិស ខាងកើតព្រះបរមរាជវាំងមានសេដ្ឋី ១ ពាន់ជាបរិវារ ទេវបុត្ត ១ ពាន់អង្គ ទៀតក៏ចុះមកចាប់បដិសន្ធិក្នុងផ្ទៃនៃសេដ្ឋីជាបរិវារដែរ កុមារទាំងនោះជា បរិវារព្រះពោធិសត្វទាំងអស់ ៗ ឯសក្កទេវរាជទ្រង់យកថ្នាំទិព្វមកដាក់នឹង ព្រះហស្តព្រះពោធិសត្វ ៗ លុះព្រះពោធិសត្វនិងកុមារទាំងនោះ នៅ ក្នុងគភ៌គ្រប់ ១០ ខែហើយ ក៏ប្រសូតដំណាលគ្នាទាំង ១ ពាន់ ១ នាក់ ៗ នាងសុមនាទេវីឃើញឱសថនៅបាតព្រះហស្តបុត្រដូច្នោះ ក៏សួរថាៈ កូនឯងបានអ្វីកាន់ក្នុងដៃ? សូម្បីកុមារទើបតែប្រសូតភ្លាម ក៏ចេះស្ដីតប នឹងមាតាថាៈ បពិត្រព្រះមាតា នេះជាថ្នាំទិព្វ ៗ កាលនោះសិរីវឌ្ឍសេដ្ឋីជា បិតាមានរោគឈឺក្បាលអស់ ៧ ឆ្នាំហើយព្យាបាលមិនទាន់ជាសោះ ទើប

នាងសុមនាទេវី យកថ្នាំទិពនោះទៅដុះឲ្យស្វាមីពិសារលមើល លុះពិសាភ្លាមក៏ជាមួយរំពេច ទោះមនុស្សដែលមានរោគអ្វីៗ ក៏ដោយ ឲ្យតែបានផឹកថ្នាំនេះក៏ជាសះស្បើយទាំងអស់គ្នា ហេតុនេះបានជាមាតាបិតាសន្មតិនាមថា: មហោសថកុមារ ។ លុះព្រះជន្មបាន ៧ ឆ្នាំកុមារទាំង១ពាន់នាក់មកធ្វើជាបរិវារទាំងអស់គ្នា ។ សម័យមួយ ព្រះបរមពោធិសត្វប្រាប់កុមារទាំងអស់ឲ្យយកមាស ១ ដម្លឹងម្នាក់ៗ (ត្រូវជា ១ ពាន់ដម្លឹង) ទៅជួលជាងសង់សាលា ៥ ខ្នងគឺសាលាសម្រាប់ឈ្មួញ ១ ។ សម្រាប់សមណព្រាហ្មណ៍ព្រឹទ្ធាចារ្យ ១ សម្រាប់មនុស្សទុគ៌តនិងស្រីមានគភ៌ ១ សម្រាប់ប្រជុំកាត់អាថ៌ប្រស្នា ១ សម្រាប់លេងល្បែង ១ ហើយឲ្យគូររូបក្បូរក្បាច់រចនាល្អស្អាត ឲ្យជីកស្រះមានកំពង់ ១ ពាន់ ដាំផ្កាលេចមានពណ៌ ៥ ដូចជានន្ទវនឧទ្យានស្ថានសួគ៌ ។

ចំណែកព្រះរាជាទ្រង់នឹកក្នុងដល់ពាក្យទំនាយដែលអាចារ្យទាំង ៤ នាក់ទាយថ្វាយ ទ្រង់ក៏ចាត់អាមាត្យ ៤នាក់ឲ្យចេញស៊ើបរកអ្នកប្រាជ្ញ ។ អាមាត្យម្នាក់ដើរទៅទិសខាងកើត បានឃើញសាលាទាំង ៥ និងស្រះទាំងកំពង់១ពាន់ល្អឥតមានមនុស្សណាធ្វើបាន មានតែអ្នកប្រាជ្ញទើបកសាងបែបនេះបាន ក៏ពិចារណារាប់ដៃគិតតាំងពីព្រះរាជា ទ្រង់សុបិននិមិតមកដល់ឥឡូវនេះ ត្រូវជា ៧ ឆ្នាំគត់ កំណត់ហេតុដូច្នេះបានហើយក៏ទៅក្រាបទូលព្រះរាជាតាមដំណើរនោះ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយក៏ត្រាស់ឲ្យហៅអាចារ្យទាំង ៤ មក

សួរថា: តើយើងល្មមទៅយកមហោសថកុមារមកដាក់ទុកជាអ្នកប្រាជ្ញហើយឬនៅ? អាចារ្យទាំង៤ មានចិត្តឥច្ឆា ខ្លាចខាតលាភសក្ការនិងយសសក្តិ ក៏ទូលតបថា: ក្រាបទូលមិនទាន់ល្មមទេ ព្រះរាជាក៏ទ្រង់គង់ស្ងៀម ៗ លុះកាលខាងក្រោយមកព្រះបាទវិទេហរាជទ្រង់តាត់ទូលឲ្យទៅស៊ើបម្តងទៀត បានឃើញមហាជនកំពុងល្បងមើលប្រាជ្ញាគឺ...:

សម័យមួយ ព្រះបរមពោធិសត្វដើរទៅកាន់សាលាសម្រាប់លេងល្បែង ពេលនោះមានមហាជនជាច្រើននៅនឹងសាលាហើយហាលសាច់ពង្វជុំក្ការ ស្រាប់តែមានសត្វខ្លែងមួយ វាហើរមកចឹកយកទៅ ឯក្មេងជាបរិវារនៃព្រះពោធិសត្វ ក៏ស្រែកហៅគ្នាឲ្យដេញយកសាច់ពីខ្លែងនោះវិញ ចំណែកខ្លែងនោះឃើញក្មេងរត់ដេញដូច្នោះក៏បេះតែហើរទៅឆ្ងាយ ពួកក្មេងទាំងនោះខំរត់តាមខ្លែងជំពប់ជើងនឹងដីដុំប៉ះនឹងកំណាត់ឈើជាដើម ក៏នៅតែខំរត់ដេញទៅទៀត ៗ

កាលនោះព្រះពោធិសត្វ ប្រាប់ទៅក្មេងទាំងអស់នោះថា៖

ម្នាលអ្នកទាំងឡាយ ចូរអ្នកទាំងឡាយមើលអញៗ នឹងដេញខ្លែងនោះឲ្យគិតភ័យបោលដុំសាច់ស្លូវនេះ ពួកមហាជនក៏ស្រដីថា: សូមអម្ចាស់ធ្វើឲ្យខ្លែងនេះលែងដុំសាច់នោះមើល ព្រះពោធិសត្វតបហើយឆ្លើយថា: បើដូច្នោះចូរអ្នកទាំងឡាយចាំមើល ពោធិសត្វក៏ចុះអំពីសាលារមិលមើលទៅខាងលើ ហើយរត់តាមដោយកំលាំងលឿនជាក្រៃលែង លុះឃើញស្រមោលខ្លែងនោះហើយ ក៏ទះប្រហស្តទាំងពីរ ហើយស្រែកយ៉ាងខ្លាំង

សត្វម្រែកនោះពាំទៅដល់ក្មេងកាលណា ហាក់ដូចជាពុះទំលាយនៅថ្ងើមបេះដូង ស្រាបតែរឹងស្វាច់ហើយទៅទៀតពុំរួច ដោយគេដះព្រះអង្គ ពោធិសត្វឃើញខ្លួននោះរឹងស្វាបនៅនឹង ជម្រុះដំសាច់ដូងខ្ទោះ កំស្រុះឡើង



ទៅទទួលអំពីកណ្តាលអាកាស ដើម្បីកុំឲ្យជំសាច់ជ្រុះដល់ដី ពួកមហាជន ឃើញអស្ចារ្យដូច្នោះ ក៏ស្រែកញ្ជ្រំពងឲ្យពរសព្វសាធុការគ្រប់ៗគ្នា ។ រាជអាមាត្យស៊ើបការឃើញហេតុដូច្នោះហើយ ក៏ទៅទូលព្រះរាជាតាមដំណើរនោះ ៗ ព្រះរាជាទ្រង់ជ្រាបហើយ ក៏ហៅអាចារ្យទាំង ៤ មកសួរថា: យើងល្មមទៅយកអ្នកប្រាជ្ញនោះមកដំកល់ទុកក្នុងទីនេះហើយឬនៅ ? អាចារ្យទាំង៤ មានចិត្តឥច្ឆា ក៏ក្រាបទូលថាមិនទាន់ល្មមទេ ។ ស្តេចក៏ប្រើរាជទូតឲ្យប្រាប់អាមាត្យនោះឲ្យចាំស៊ើបមើលទៀត ។

នៃមួយទៀតដំណាលថា: មានបុរសកំសត់ម្នាក់ ចិញ្ចឹមជីវិតនៅក្នុងស្រុកមួយ លុះដល់ខែភ្លៀងធ្លាក់ជោកជាំ បុរសនោះក៏គិតថាឥឡូវនេះមានភ្លៀងហើយ តើអញបានគោក្របីអំពីណាធ្វើស្រែនឹងគេ គិតដូច្នោះហើយ ក៏យកមាសប្រាក់ដើររកទិញគោអំពីស្រុកឯទៀត លុះបានហើយក៏នាំមកកាន់ផ្ទះវិញ ដល់ព្រឹកឡើងបុរសនោះដឹកគោទៅឲ្យស៊ីស្មៅ នៅកន្លែងមួយ ដល់ហើយក៏លែងគោនោះឲ្យស៊ី ហើយនៅដេកក្រោមដើមឈើលុះត្រូវខ្យល់រំភើយ ៗ ក៏លក់ទៅ ពេលនោះមានអាចោរម្នាក់មកលួចយកគោនោះ បុរសភ្ញាក់ឡើងក្រឡេកមើលមិនឃើញគោក៏ស្ទុះក្រោកម្នីម្នារមើលខាងណេះខាងណោះ ស្រាប់តែឃើញអាចោរកំពុងបំបោលគោនោះទៅ បុរសម្ចាស់គោនោះក៏រត់តាម លុះជិតនឹងទាន់ក៏ស្រែកហៅថា: អើយ ៗ ដឹកគោអញយកទៅណា ចោរនោះឮសំដីនោះហើយក៏ឆ្លើយទៅវិញថា: យើ ! ឯណាគោប្រស្តន គោនេះ

ជាគោរបស់អញទេតើ ម្តេចក៏ហ៊ានមកថាគោរបស់ប្រស្តង ? បុរសទាំងពីរនាក់នោះក៏កើតជាពាក្យជំលូសឈ្លូសប្រកែកគ្នាទៅវិញទៅមក ៗ ពួកមហាជនទាំងពួងបានឮពាក្យនោះហើយក៏ជំនុំគ្នានៅក្នុងបរមសាលានៃចៅអ្នកប្រាជ្ញ លុះបុរសទាំងពីរនាក់នោះទៅដល់ទ្វារសាលានោះហើយ ទើបព្រះពោធិសត្វឲ្យហៅចូលមក ព្រះពោធិសត្វគ្រាន់តែឃើញមុខក៏ស្គាល់ដោយប្រាជ្ញាច្បាស់ថា: បុរសនេះជាចោរ បុរសនេះជាម្ចាស់ ៗ ពោធិសត្វ សូម្បីដឹងច្បាស់យ៉ាងណាក្តី ក៏ធ្វើហាក់ដូចជាមិនដឹងវិញទើបទ្រង់សួរថា: ម្នាលបុរសទាំងពីរអ្នកឯងនេះធ្វើពាក្យជុំលួសឈ្លោះប្រកែកគ្នានេះតើដោយហេតុអ្វី ? បុរសជាម្ចាស់គោទូលថា: បពិត្រព្រះបាទម្ចាស់ ខ្ញុំទិញគោ អំពីស្រុកមានឈ្មោះដូច្នេះ ៗ ហើយខ្ញុំនាំមកទុកនៅផ្ទះ លុះព្រឹកឡើង ក៏នាំយកទៅរកកន្លែងមានស្មៅល្អរួចខ្ញុំលែងគោនេះឲ្យស៊ី ហើយខ្ញុំមកដេកនៅក្រោមម្លប់ឈើ ខ្ញុំដេកលក់ពេលណាហើយបុរសនេះ យកគោខ្ញុំនាំបណ្តើតទៅ ៗ ចោរនោះទូលថា: បពិត្រអម្ចាស់គោខ្ញុំនេះវាកើតក្នុងផ្ទះខ្ញុំ គាត់នេះមកនិយាយស្រដីពាក្យកុហកកូតករទេ គោរបស់ខ្ញុំទេម្ចាស់ ៗ មហោសថអ្នកប្រាជ្ញសួរទៅបុរសទាំងពីរថា: ម្នាលបុរសទាំងពីរឥឡូវនេះចូរអ្នកឈប់ស្ទះ រឿងក្តីនេះសិនចុះ ចូរប្រស្តងទាំងពីរចាំស្តាប់បង្គាប់របស់ខ្ញុំ បុរសទាំងពីរ ក៏នៅស្ងៀមប្រុងចាំស្តាប់ព្រះពោធិសត្វគិតថា គួរអញលបចិត្តបុរសទាំងពីរនេះហើយក៏សួរទៅចោរនោះជាមុន ថាម្នាលបុរស

គោប្រែស្គន៍នេះឲ្យស៊ីចំណីអ្វីខ្លះ ? អាចារ្យនោះឆ្លើយថា: គោនេះខ្ញុំឲ្យស៊ីតែបបរ នឹងស្ករសន្ធកទើបព្រះពោធិសត្វឲ្យកត់ពាក្យសំគាល់ស្រេចហើយ ទើបទ្រង់សួរទៅម្ចាស់គោទៀត បុរសនោះឆ្លើយថា: បពិត្រអម្ចាស់ ខ្ញុំជាមនុស្សកំសត់ទុគ៌តដូច្នេះនឹងបានបបរឯណាឲ្យគោនេះវាស៊ី គោខ្ញុំនេះឲ្យស៊ីតែស្មៅនឹងស្លឹកឈើផ្សេង ៗ ៗ ទើបព្រះពោធិសត្វឲ្យកត់ពាក្យបុរសទាំងពីរនាក់នោះស្រេចហើយ ទើបប្រើបុរសម្នាក់ជាអ្នកសម្រាប់ប្រើរបស់ខ្លួន ឲ្យយកទឹកដាក់នឹងថាសស្រេចហើយ ឲ្យយកប្រយង្គមកប្រឡាក់នឹងទឹក ហើយឲ្យយកទៅឲ្យគោនោះផឹក ៗ គោនោះ ផឹកទៅពេលណា ហើយក៏ក្អួតបង្អោរចេញមកសុទ្ធតែស្មៅតែម្យ៉ាង ទើបចៅអ្នកក្រាជ្ញ សួរទៅមហាជនទាំងឡាយថា: ម្នាលអ្នកទាំងឡាយអ្នកមើលមើ ? ៗ ទើបព្រះពោធិសត្វសួរទៅចោរថា ម្នាលបុរស ប្រែស្គន៍ជាចោរឬ ? ឬមិនមែន ? អាចោរឆ្លើយថា: បពិត្រអម្ចាស់ដ៏ចំរើន ខ្ញុំនេះជាចោរពិតហើយ ៗ ទើបព្រះពោធិសត្វ ឲ្យវាយដំជើងដៃបុរសនោះឲ្យថយកំលាំង ទើបឲ្យដម្បូន្មានថា ម្នាលបុរសចូរប្រែស្គន៍ យល់ទុកនាលោកិយពីបាកប៉ុណ្ណេះថា: ពីបាកអ្វីបើប្រែស្គន៍ទៅសោយទុក្ខវេទនា ក្នុងមហានរកនោះពីបាកដ៏ក្រៃលែងលើសនេះទៅទៀត ៗ ចាប់ដើមតាំងពីថ្ងៃនេះទៅ ចូរប្រែស្គន៍កុំធ្វើអំពើដូច្នេះទៀត ៗ រាជអាមាត្យលុះបានដឹងសព្វគ្រប់ក៏ឲ្យនាំពត៌មាននោះទៅទូលព្រះបាទវិទេហរាជ ព្រះរាជាទ្រង់សួរថា: ម្នាលអាចារ្យសេនក ឥឡូវ



នេះតើយើងនឹងឲ្យទៅយកចៅអ្នកប្រាជ្ញនោះមកឬ? ឬដូចម្ដេច? ទើបអាចារ្យសេនកទូលថាៈ បពិត្តអំម្ចាស់ មនុស្សយើងបើគ្រាន់តែចេះពិចារណាសេចក្ដី គឺលួចគោដូច្នេះលោកមិនរាប់ហៅថាអ្នកប្រាជ្ញឡើយ បុរអម្ចាស់ស្ទេះទុកសិនចុះ ។

ឯព្រះបាទវិទេហរាជ ស្ដេចគង់នៅស្ងៀម ហើយស្ដេចឲ្យនាំពត៌មានទៅកាន់រាជអាមាត្យនោះវិញ ឯវំ (ការណំ រីហេតុនេះ បណ្ឌិតេន គឺបណ្ឌិត វេទិតព្វំ គប្បីដឹង),

## ឯកា បន ទុគ្គតិ ឥត្ថី នានាវណ្ណេហិ សុត្តេហិ

កាលនោះមានស្រីម្នាក់កំសត់ទុគ៌ត មានបំណងនឹងចង់តុបតែងប្រដាប់ពង់កាយអាត្មា ក៏យកអាម្បោះមកចងជាសង្វា ឆ្លាស់ពណ៌ផ្សេង ៗ ស្រេចហើយស្រីនោះពាក់នូវក ហើយដើរទៅងូតទឹកឯស្រះបោក្ខរណីនៃព្រះមហោសថអ្នកប្រាជ្ញ លុះដើរទៅដល់ស្រះបោក្ខរណីកាលណាក៏ផ្លាស់សំពត់អំពីបង្កេះ ដោះសង្វារអំពីកដាក់លើសំពត់ ហើយស្រីនោះឯងចុះទៅងូតទឹក ប្រយោជន៍ដើម្បីនឹងបន្ទោរបង់នូវញើសក្អែល ៗ កាលនោះមានស្រីក្រមុំម្នាក់ទៀតដើរមកដល់មាត់ស្រះ ឃើញសង្វារនោះហើយបង្កើតចិត្តស្រឡាញ់ លោភចង់បានសង្វារនោះ ក៏និយាយទៅនឹងស្រីជាម្ចាស់សង្វារថា: សម្លាញ់ ៗ!! សង្វារនេះតើធ្វើខ្លួនឯងឬ? ឬជួលអ្នកដទៃធ្វើ? ស្ត្រីជាម្ចាស់សង្វារឆ្លើយថា សម្លាញ់អញធ្វើខ្លួនឯងទេ ស្រីកំណាចនោះថា សុំមើលបន្តិចបានទេ? នាងនោះថា. មានអ្វីសំឡាញ់មើលចុះ ៗ ស្រីកំណាចនោះយកសង្វារមកពាក់នូវករួចហើយ ឃើញស្រីជាម្ចាស់សង្វារក្រវើនតែងូតទឹក ពុំបានជាចាប់គិតរមិលមើល, មេកំណាចនោះយកសង្វារនោះរត់ទៅ ស្រីជាម្ចាស់សង្វារ ក៏ពុំបានជាចាប់គិតនឹកដល់សង្វារ ស្រាបតែនឹកឃើញហើយក្រឡេករកមើល

ស្រីនោះមិនឃើញ ក៏ឡើងមកអំពីស្រះបោក្ខរណី ១ រំពេច ហើយ ផ្លាស់សំពត់ស្ទើរពុំទាន់ ក៏ម្នារត់តាមទៅ ទាន់ហើយក៏ចាប់ដាយសំពត់មេកំណាចនោះ ហើយស្រដីទៅថាហានយកសង្វារអញទៅណា?

ស្រីកំណាចឆ្លើយថា: យី!! មេះនេះមកអំពីណាឥតក៏លលាក់លលើរអ្វី មេះ សង្វារនេះអញប្រដាប់ប្រដារចនាអំពីទីស្ថានលំនៅអញទេតើ ស្ត្រីទាំងពីរនាក់ក៏បង្កើតជាពាក្យជំលូសឈ្លោះប្រកែកគ្នាទៅវិញទៅមកពុំដាចស្រេចក៏បណ្តើរគ្នាទៅប្តឹងពោធិសត្វ លុះដើរទៅទៀបទ្វារសាលានៃព្រះពោធិសត្វមួយអន្ទើរដោយក្មេងចំនួន ១០០០ នាក់ចោមរោមជាបរិវារ ទើបព្រះពោធិសត្វឲ្យហៅស្រីទាំងពីរនាក់ចូលមក លុះស្រីទាំងពីរជំរាបរឿងហេតុរួចហើយ ទ្រង់ក៏ស្គាល់ដោយប្រាជ្ញាច្បាស់ថា: ស្រីនេះជាចោរ ស្រីនេះជាម្ចាស់សង្វារ ៗ តែព្រះអង្គទ្រង់ចង់រកឲ្យអស់ចិត្ត ទើបព្រះអង្គមានព្រះបន្ទូលសួរថា: នែអ្នកទាំងសងខាង បើដូច្នេះអ្នកស្តាប់បង្គាប់អញឬ? ឬដូចម្តេច ស្រីទាំងពីរនាក់នោះក៏ឆ្លើយថា: ខ្ញុំស្តាប់បង្គាប់របស់អម្ចាស់ ទើបព្រះពោធិសត្វទ្រង់ញញឹម ៗ ក៏សួរទៅស្រីជាចោរនោះជាមុនថា: នែនាង! សង្វាររបស់នាងនេះតើនាងតែងទឹងអប់នូវក្លិនអ្វី? ស្រីជាចោរនោះទូលថា: បពិត្រអម្ចាស់ !! ខ្ញុំតែងអប់នូវក្លិនពិដោរផងទាំងពួង គឺក្រេបះបួងច័ន្ទជាប្រិក្រតី ព្រះពោធិសត្វជ្រាបហើយឲ្យកត់ពាក្យនោះទុកសំគាល់ ក៏ទ្រង់សួរទៅស្រីជាម្ចាស់សង្វារទៀតនាងម្ចាស់សង្វារថា: បពិត្រម្ចាស់ ខ្ញុំគ្មានក្រេបះបួងច័ន្ទឯណាទេ !! ខ្លួនខ្ញុំនេះជាអ្នកកំសត់ទុគ៌ត ពិបាកជាពន់

ពេក ! ខ្ញុំយកតែផ្កាប្រយង្គុមកអប់នូវសព្វថ្ងៃជាប្រក្រតី ៗ មហោសថ ស្តាប់ពាក្យស្រីទាំងពីរនោះហើយ ឲ្យយកភាជនៈមាស មកចាក់បំពេញនូវទឹកហើយយកសង្វារដាក់ក្នុងទឹកនោះ ទើបមានបន្ទូលឲ្យហៅជាង មកពិចារណាក្លិនសង្វារនោះតើក្លិននេះ ជាក្លិនក្របេះបួងប័ន្ទឬ ? ឬជាក្លិនប្រយង្គុផ្កា ជាងក៏ពិចារណាក្លិនសង្វារមិនធុំក្លិនក្របេះបួងប័ន្ទសោះ សុភាពជាធុំក្លិនប្រយង្គុផ្កាជាប្រកដ ហើយជាងទូលព្រះពោធិសត្វថា: មិនធុំក្លិនក្របេះបួងប័ន្ទទេ ធុំក្លិនតែផ្កា ប្រយង្គុផ្កា:នោះជាប្រាកដ ៗ

ព្រះពោធិសត្វ ជ្រាបនូវហេតុនោះហើយ ទើបមានបន្ទូលសួរទៅស្រីលួចសង្វារថា: ម្នាលនាង ? នាងថាខ្លួនជាម្ចាស់សង្វារ អប់នៅក្របេះបួងប័ន្ទ ឥឡូវនេះមិនធុំក្លិននោះ ទ ធុំតែក្លិនប្រយង្គុផ្ការ បើដូច្នេះនាងជាចោរលួចសង្វារគេហើយ ៗ មេកំណាចស្តាប់ព្រះបន្ទូលព្រះពោ-ធិសត្វហើយ ពុំអាចនឹងហ៊ានលាក់ក៏ទូលព្រះពោធិសត្វវិញថា: អម បពិត្រព្រះមហោសថ ដចំរើន ខ្ញុំនេះជាចោរលួចសង្វារគេពិតមែន ៗ ចាប់ដើមអំពីថ្ងៃនេះទៅ អស់មហាជនទាំងពួងដឹងជាក់ច្បាស់ថា: ព្រះមហោសថជាអ្នកប្រាជ្ញពិតទៗ ៗ ទើបព្រះពោធិសត្វ ឲ្យឱវាទដល់ស្រីជាចោរលួចសង្វារនោះថា: នែនាងចាប់តាំងពីថ្ងៃនេះទៅនាងកុំធ្វើជាចោរលួចគេទៀត ក្នុងបច្ចុប្បន្ននេះនាងនឹងខ្មាស់គេ ? ដល់បរលោកនាយទៅ នាងនឹងសោយទុក្ខវេទនា ក្នុងនរកនាយជាមិនខានឡើយ ៗ អាមាត្យក៏នាំពត៌មានទៅទូលព្រះរាជា ៗ បានជ្រាបហេតុនោះសព្វគ្រប់ ក៏មានព្រះទ័យសោមនស្ស



ត្រេកអរជាពន់ពេក ហើយមានព្រះបន្ទូលទៅកាន់អាចារ្យសេនកថាៈ ម្នាលអាចារ្យ ឥឡូវនេះរាជអាមាត្យ ឲ្យរាជទូតមកប្រាប់អញថាៈ មហោសថមានបញ្ញាចេះរករឿងហេតុនៃស្រីពីរនាក់ លួចសង្ហារគ្នាឃើញដោយប្រាកដណាស់ ថាស្រីនេះជាម្ចាស់សង្ហារ ស្រីនោះជាចោរលួច-សង្ហារ បើដូច្នោះតើយើងឲ្យទៅយកមកដំកល់ទុកជាអ្នកប្រាជ្ញឬ? អាចារ្យសេនក ស្តាប់ហើយទូលថាៈ សូមទ្រង់ព្រះមេត្តាប្រោះ មហោសថ បុគ្គ

សិរីវឌ្ឍន៍ បេះតែពិចារណាសេចក្ដីប៉ុណ្ណោះ បណ្ឌិតលោកមិនអាចរាប់ថាជាអ្នកប្រាជ្ញបានឡើយ ៗ ថាបើសព្វព្រះរាជហឫទ័យនឹងមហោសថ ចុះស្រុកក្រៅ ចៅសុភាសិតមានបញ្ញា បេះជំនុំក្ដីអ្នកផងទាំងពួងបានដែរ សូមយកមកដំកល់ទុកធ្វើជាអ្នកប្រាជ្ញនោះប្រសើរជាង ៗ មហាក្សត្រស្ដាប់ពាក្យអាចារ្យសេនកហើយមានព្រះបន្ទូលប្រាប់ទៅរាជទូតថា ម្នាលរាជទូតបូរឯងវិលទៅប្រាប់រាជអាមាត្យឲ្យរាំចាំឃ្លាំមើល បើមានរឿងអ្វីផ្សេងៗ ទៀត បូរឲ្យមកប្រាប់អញ ៗ

កាលនោះមានស្រីម្នាក់រក្សាចំការកប្បាស ស្រីនោះឯងតែងបេះកប្បាសរើសយ៉ាងល្អហើយក៏រវៃធ្វើជាអម្បោះយ៉ាងឆ្មារល្អហើយ យកមកដាក់កញ្ជើ នៅក្នុងកញ្ជើមានដាក់គ្រាប់ទន្ទាប់លុះរៀបចំរួចក៏កណ្ដៀតដើរទៅកាន់ផ្ទះអាត្មា ៗ

លុះទៅដល់ស្រះព្រះមហោសថ ក៏ដាក់កញ្ជើចុះ ហើយផ្លាស់សំពត់ ដាក់ជិតកញ្ជើនោះចុះទៅងូតទឹក ៗ កាលនោះមានស្ត្រីម្នាក់ទៀតដើរមក ឃើញអម្បោះឆ្មារល្អ ក៏មានចិត្តលោភចង់បាន ហើយស្រីដីថាម្នាលសម្លាញ់អម្បោះនេះឆ្មារល្អម្ល៉េះ សូមមើលបណ្ដិចបានឬទេ មាត់ថាដៃទៅស្ទាបអង្អែលកាន់មើល កាលនោះស្រីជាម្ចាស់អម្បោះក្រើនតែងូតទឹកពុំបាននិយាយថាអ្វី មេកំណាចក៏យកកញ្ជើនោះកណ្ដៀតដើរទៅ ឯស្ត្រីម្ចាស់អម្បោះនោះ ក្រឡេកទៅឃើញដូច្នោះហើយ ក៏ឡើងម្នីម្នារត់តាមទៅ ចាប់បណ្ដើរគ្នាមកប្ដឹងព្រះពោធិសត្វ ៗ ពោធិសត្វអ្នកប្រាជ្ញ សួរទៅស្រីជាចោរកំណាចមុនថាអើ !

នាង១ ថាកញ្ចើអំបោះនេះជារបស់នាង  តើក្នុងកញ្ចើនេះនាងដាក់អ្វីខ្លះ ? មេកំណាចមកគិតពិចារណាថា: អ្នកចំការនេះមុខជាដាក់គ្រាប់កប្បាស គិតដូច្នោះហើយក៏ជំរាបពោធិសត្វថា:  ខ្ញុំដាក់គ្រាប់កប្បាស ព្រោះពោធិសត្វឲ្យកត់ពាក្យនោះទុក ។  ទើបសួរទៅស្រីជាម្ចាស់កប្បាសទៀត ស្រីជាម្ចាស់កប្បាសនោះឆ្លើយថា:  បពិត្រព្រះមហាសត្វ  ក្នុងកញ្ចើនេះ



ខ្ញុំដាក់គ្រាប់ទន្ទាប់ ដ្បិតខ្ញុំនឹងសង្កិតអំបោះ ទើបពោធិសត្វឲ្យកត់ពាក្យ
ស្រីនោះ ៗ ហើយក៏រើកកញ្ជើឡើង ឃើញតែគ្រាប់ទន្ទាប់ ទើបព្រះ
ពោធិសត្វនិយាយទៅនឹងស្រីជាចោរនោះថា: នែនាង ! នាងឯងថា
ដាក់គ្រាប់កប្បាសក្នុងកញ្ជើ ឥឡូវរើទៅមិនឃើញគ្រាប់កប្បាសសោះ
ឃើញតែគ្រាប់ទន្ទាប់ទៅវិញ បើដូច្នេះតើនាងជាចោរឬ ? ឬមិនមែន ?
ស្រីនោះពុំអាចលាក់ខ្លួនបាន ក៏សុំទោសព្រះពោធិសត្វថា: បពិត្រលោក
ម្ចាស់ដ៏ចំរើន ខ្ញុំនេះជាចោរពិតមែន ៗ ព្រះមហោសថ ប្រដៅស្រី
កំណាចនោះស្រេច, ទើបព្រះអង្គឲ្យកញ្ជើនោះទៅស្រីជាម្ចាស់អំបោះ
នោះវិញទៅ នាងជាម្ចាស់អំបោះទទួលកញ្ជើស្រេចហើយក៏ឲ្យពរសព្ទ
សាធុការដល់ព្រះពោធិសត្វ ហើយក្រាបលាវិលទៅកាន់ស្ថានលំនៅរបស់
ខ្លួនវិញទៅ ៗ អស់មហាជនទាំងឡាយ យល់ឃើញក៏មានចិត្ត
សោមនស្សរីករាយត្រេកអរជាគេរយោភាព ក៏ទះដៃឲ្យពរជ័យសព្ទសា
ធុការគឹកគង ជាយជាពន់សែន ! ៗ រាជអាមាត្យដែលមហាក្សត្រ
ប្រើមកឲ្យឃ្លាំចាំមើលឃើញសេចក្តីអស្ចារ្យ មិនវិស័យជាក្មេងអាយុ៧ឆ្នាំ
ហាក់ដូចជាមនុស្សធំក៏ប្រើរាជទូតស្រូតទៅទូល ព្រះបាទវិទេហរាជស្តេច
ជ្រាបច្បាស់ហើយ មានព្រះដម្រាសត្រាស់ហៅអាចារ្យសេនក មកសួរ
ដូចមុនទៀត ៗ អាចារ្យសេនក ក៏ទូលទាស់ព្រះមហាក្សត្រមិនឲ្យទៅ
នាំពោធិសត្វមកឡើយ ៗ

និយាយអំពីស្រីម្នាក់ទៀត ពរកូនទៅងូតទឹកកាលបើដើរទៅដល់ស្រះមហាសថហើយក៏ផ្លាស់សំពត់ ពរកូនចុះទៅងូតលាងមុខមាត់កូនស្រេចរួចហើយ យកមកឲ្យគង្គុយលើសំពត់នៃខ្លួន ហើយចុះទៅងូតទឹកខ្លួនឯងទៀត ពេលនោះ ស្រាប់តែមានយក្ខិនីម្នាក់ដើរមកឃើញកូនតូចនោះ មានបំណងចង់ស៊ី ក៏ក្លែងខ្លួនធ្វើជារូបស្រីម្នាក់ ហើយនិយាយទៅថា ហៃនាងសម្លាញ់! ក្មេងនេះល្អតល្អម៉្លេះ តើក្មេងនេះជាកូននាងឬ? ម្ដាយនោះត្កហើយក៏ឆ្លើយទៅថា កូនរបស់អញ, យក្ខិនីថាអញបំបៅបន្តិចបានទេ? នាងថាបំបៅក៏បំបៅចុះ យក្ខិនីនោះត្កហើយពយកក្មេងនោះធ្វើហាក់ដូចជាបំពេរ បន្ទងទៅមកបន្តិចបីក្មេងនោះយកទៅ ៗ ឯម្ដាយនោះឃើញគេយកកូនទៅដូច្នោះ ក៏ឡើងអំពីទឹកម្នីម្នាប្រញាប់ចាប់បានសំពត់យកមកស្លៀកហើយក៏រត់ទៅតាមស្រែកហៅនាងនោះថា ហែងយកកូនអញទៅណា? ស្រីនោះរត់ទាន់ក៏ចាប់ជាយសំពត់ជាប់, យក្ខិនីនិយាយថា នាងបានកូននេះពីណាមក កូនអញទេតើ! នាងនឹងយក្ខិនីក៏ឈ្លោះគ្នា នៅជិតមាត់ទ្វារបរមសាលានៃព្រះពោធិសត្វ កាលនោះព្រះពោធិសត្វទ្រង់ឮពាក្យស្រីនឹងយក្ខិនីនោះដដែកគ្នា ទើបទ្រង់ហៅមក សួរថា: ហេតុការណ៍ដូចម្ដេចបានជាទាស់គ្នា? ឯស្រីនោះប្រាប់សេចក្ដី សប់គ្រប់ទើបពោធិសត្វស្គាល់ថា: មេនេះជាយក្ខិនី ដ្បិតខ្លួនពុំប្រុះកដេ ហើយពុំមានភ្នែកក្រហម១, ពុំឥតញើស១ឥតស្រមោល១ ទើបព្រះពោធិសត្វថា: នែនាងទាំងពីរ ចូរស្ដាប់បង្គាប់អញឯណេះវិញ

ស្រីទាំងពីរនោះថាបពិត្រអម្ចាស់យើងខ្ញុំទទួលស្ដាប់បង្គាប់របស់អម្ចាស់ ។

ព្រះពោធិសត្វត្រាប់សព្វគ្រប់ទើបទ្រង់គូសដីជាវង់ ហើយឲ្យយកកូនមកដេកចំកណ្ដាលគំនូសនោះ ហើយឲ្យយក្ខិនីកាន់ដៃ ម្ដាយឲ្យកាន់ជើង រួចត្រាប់ថា: បើនរណាទាញបាន យើងដឹងថា: កូននោះជារបស់អ្នកនោះ ស្រីជាម្ដាយនឹងយក្ខិនីទាញទៅទាញមក កូននោះដោយរាំពីបាកខ្លាំងពេកក៏ស្រែកយំយ៉ាងខ្លាំង បំណែកម្ដាយរបស់បុត្រលុះឮកូននោះយំដូច្នោះតឹងទ្រូងស្ទើរនឹងបែកក៏ឈរយំកង្ទីនោះដែរ ព្រះមហាសត្វសួរអស់មហាជនទាំងឡាយទាំងពួងថា: ម្នាលអ្នកទាំងឡាយ ហឫទ័យរបស់ម្ដាយទន់នឹងបុត្រទេឬ ឬមិនទន់ ? មហាជនទាំងឡាយក៏ឆ្លើយថា: បពិត្រព្រះមហាសត្វ, ហឫទ័យរបស់ម្ដាយបង្កើតរបស់កូន ទន់នឹងកូនណាស់ ។ មហាសត្វសួរទៀតថា: ស្រីកាន់កូនហើយឈរឆ្ងើប្រងើយនេះ តើជាម្ដាយរបស់បុត្រនេះឬ ? ឬមិនមែន ? ឬមួយដែលឈរស្រែកយំនេះជាម្ដាយ ? មហាជនក៏ពោលឡើងថា បពិត្រព្រះមហាសត្វអ្នកប្រាជ្ញ ស្រីដែលឈរទ្រហោយំនេះជាម្ដាយ ទើបមហាសត្វថា: អ្នកទាំងឡាយស្គាល់ចោរលួចកូននេះទេ ? មហាជនឆ្លើយថា: យើងទាំងអស់គ្នាពុំស្គាល់ទេ , ទើបព្រះមហាសត្វបន្ទូលសំដែងឡើងថា: ម្នាលគ្នាយើងទាំងឡាយស្រីនេះជាយក្ខិនីទេតើ រាំចាប់យកកូននេះទៅស៊ី មហាជនសួរថា: បពិត្រអ្នកប្រាជ្ញ ម្ចាស់ស្គាល់ស្រីនេះជាយក្ខិនីនោះ តើចំណាំលក្ខណៈដូចម្ដេច?

មហាសេដ្ឋថា: មិនប៉ប្រិចភ្នែកនោះ ១, មានភ្នែកក្រហមនោះ ១, ឥតស្រមោលខ្លួននោះ ១, ពត់តញ្ញើត ១, ទើបមហាសេដ្ឋសួរទៅយក្ខិនីទៀតថា: នាងជាអ្វី? យក្ខិនីនឹកថាគេដឹងអស់ហើយបើលក្ខកពុំកើតម្លោះហើយប្រាប់តាមត្រង់ថា: ! ខ្ញុំនេះជាយក្ខិនី, ចុះយកក្មេងនេះទៅធ្វើអ្វី? –ឆ្លើយថា:ខ្ញុំយកទៅបំរុងនឹងស៊ី ។ ព្រះមហាសេដ្ឋឲ្យវាយដំយក្ខិនីនោះទៅហើយឲ្យដំបូន្មានថា ម្នាលយក្ខិនីនាងឯងនេះជាស្រីពាល ដូចជាខ្លាក់បានធ្វើបាបអំពីមុនទើបនាងឯងមកកើតជាយក្ខិនី អប្រិយអាស្រូវឥឡូវនេះនាងមកធ្វើបាបជាតិនេះម្តងទៀត ឱ!!នាងអើយនាងឯងល្ងង់ខ្លៅពន់ពេកណាស់ !! ។ លំដាប់នោះព្រះមហាសេដ្ឋ ឲ្យយក្ខិនីកាន់សីលប្រាំ ។ ឯម្តាយឃើញហេតុនោះហើយ ក៏សរសើព្រះមហាសេដ្ឋជាពន់ពេករួចពរកូនរបស់ខ្លួនយកទៅវិញហោង ។

ម្យ៉ាងទៀតមានសេចក្តីដំណាលថា មានបុរសម្នាក់ កណ្តាលខ្លួនខ្មៅ មានខ្នងទ្រុង កណ្តាលតូចឈ្មោះអាគោត្រកាលស៊ីឈ្នួលគេបាន ៧ ឆ្នាំទើបមានប្រពន្ធ ប្រពន្ធនោះសោត គេហៅថា: ទីឃាទាហលដ្បិតខ្ពស់ហើយធាត់ផង ។ មានកាលសម័យថ្ងៃមួយ អាគោត្រកាលមកនិយាយនឹងភរិយាថា: 'កន្ទេ, ម្នាលប្អូនសំឡាញ់ប្ងូរនាងបំអិនទុំ បំណើផ្សេង ៗ ឲ្យបងផងទីឃាទាហលជាភរិយា សួរថា: អ្នកអញ្ជើញទៅទីណា? អាគោត្រកាលឆ្លើយថា: បងទៅលេងនឹងមេបា (ឪពុកម្តាយ) របស់បងទីឃាទាហលថា: ទៅមានប្រយោជន៍អ្វី អាគោត្រកាលតោះ

សូម្បីភរិយាឃាត់ជាតំរប់ពីរ បី ដង ក៏បង្ខំឲ្យតែបំអិនខ្ញុំនឹងបំណាំផ្សេង ៗ លុះផ្អិនស្រេចអស់ហើយ ក៏នាំភរិយាដើរទៅ លុះទៅដល់ស្ទឹងមួយពក់ ប៉ុន្តែហូរខ្ទាំងបុរសនោះជាអ្នកខ្លាចទឹកណាស់ មិនអាចហ៊ានឆ្លងទឹកនោះឡើយ ដោយស្មានថាទឹកនោះជ្រៅក៏ឈប់នៅនឹងមាត់ច្រាំង ៗ

ពេលនោះមានបុរសម្នាក់ទៀត ឈ្មោះទិឃបិដ្ឋមានខ្នងវែង វាដើរមកតាមឆ្នេរស្ទឹងមកដល់កន្លែងនោះ ក៏ជួបគ្នា បុរសទាំងពីរនាក់នោះសួរគ្នាទៅវិញទៅមក រួចអាគោត្រកាលសួរថា: ម្នាលសំឡាញ់ស្ទឹងនេះជ្រៅប៉ុណ្ណា? អាទីឃបិដ្ឋ វាដឹងថា: បុរសនេះជាអ្នកខ្លាចទឹកដូច្នោះ ហើយក៏ឆ្លើយថា: ម្នាលសំឡាញ់ ទឹកនេះជ្រៅណាស់ ក្នុងទឹកនេះមានក្រពើមានត្រីគ្រប់សព្វ ៗ អាគោត្រកាល ថាម្នាលសំឡាញ់ធ្វើដូចម្ដេចនឹងទៅបាន? អាទីឃទិដ្ឋថា: សំឡាញ់ សត្វទាំងឡាយមានក្រពើនឹងផ្សោតជាដើម សត្វនោះជាឧបនិស្ស័យនឹងយើង វាពុំអាចនឹងបៀតបៀនយើងទេ បើអ្នកដទៃក្រៅពីយើងមុខជាសត្វពួកនេះយកធ្វើជាចំណីហើយ ៗ អាគោត្រកាលថា: បើដូច្នោះសំឡាញ់នឹងនាំខ្ញុំទៅខាងនោះផងបានទេ? អាទីឃបិដ្ឋ ថាយើងចំឡងបាន ពេលនោះបុរសទាំងពីរនាក់ឲ្យចំណីអាទីឃបិដ្ឋនោះបរិភោគ, លុះបរិភោគរួចហើយ អាទីឃបិដ្ឋថា: យកអ្នកណាទៅមុន? អាគោត្រកាលថា: សំឡាញ់យកម្រាក់ទៅមុនហើយសំឡាញ់មកនាំអញយកទៅជាខាងក្រោយ ៗ អាទីឃបិដ្ឋថាសំឡាញ់និយាយនេះស្រួលហើយ ហើយក៏នាំនាងទីឃា-



ទាហាល ឲ្យជិះលើស្នា ហើយយកស្បៀងទាំងពួងនោះយកទៅទាំងអស់ ស្រេចហើយក៏ចុះទៅក្នុងស្ទឹង អាទីយបដ្ឋដើរទៅបានបន្តិចក៏លុតជង្គង់ ដើរផ្ទើរកិល ៗ ហើយនិយាយថា: យី! ទឹកនេះជ្រៅណាស់ ៗ អា-គោត្រកាល ដែលឈរនៅលើមាត់ច្រាំង ឃើញអាទីយបិដ្ឋដូច្នោះ ក៏គិតថា យី! ទឹកនេះជ្រៅមែន អំបាលគេខ្ពស់ប៉ុណ្ណោះទៅហើយ បំណាន់បើអញទាបតើត្រឹមណាទៅ អាទីយបិដ្ឋ ដើរទៅដល់កណ្ដាលស្ទឹងនោះ ហើយក៏និយាយប្រឡោមលួងលោមនាងទីឃាទាហាលថា: ម្នាលប្អូន បងចង់ចិញ្ចឹមរក្សាព្យាបាលប្អូនឯង បងមានទ្រព្យសម្បត្តិច្រើន បើប្អូន

ចង់ដើរលេងឯណា ៗ ក្តី ខ្ញុំប្រុសខ្ញុំស្រី ដំរី សេះ ក្របី គោ រទេះ សម្រាប់ជូនអូនឯងដើរលេង បើប្អូននៅនឹងអាគោត្រកាលមានអ្វី បើមានដំណើរទៅណាមួយកាលដើរខ្លួនឯងលំបាកដូច្នេះ ចូរប្អូនទៅតាមបងប្រសើរជាង ឯនាងទីឃាទាហល ឮពាក្យល្អលោមដូច្នោះ ក៏កាត់ក្តីស្រឡាញ់របស់ប្តីនៃខ្លួនទៅស្នេហានឹងអាទីឃបិដ្ឋ ៗ ហើយអាទីឃបិដ្ឋសួរទៀតថា: ប្អូនឯងព្រមតាមបងឬដូចម្តេច? នាង:នោះឆ្លើយថា ខ្ញុំព្រមទៅតាមហើយបង, អាទីឃបិដ្ឋថា បើដូច្នោះ បងនឹងចិញ្ចឹមប្អូនឯងលុះត្រាអស់ជីវិត លុះឆ្លងដល់ត្រើយ នាំគ្នាអង្គុយបរិភោគអាហារយ៉ាងរីករាយ ហើយស្រែកប្រាប់ទៅថា នែ! គោត្រកាល ចូរប្រែស្តង់នៅនោះចុះ ៗ អាគោត្រកាល មើលទៅឃើញអ្នកទាំងពីរស៊ីចំណីអាហារទាំងពីរនាក់ ហេតុតែខ្លួនមិនទាន់បានឆ្លង ក៏តឹងទ្រូងស្ទើរបែកដើរចុះដើរឡើងគិតក្នុងចិត្តថា អានេះវាស្រឡាញ់ប្រពន្ធអញ ហើយវាបង់អញចោល អាគោត្រកាលក៏ចុះទៅក្នុងទឹកបន្តិចឡើងលើបន្តិចដោយចិត្តកំហឹងនឹងអ្នកទាំងពីរនោះពេក ទ្រាំមិនបានក៏បង់ក្បៀនម្នីម្នាបំរុងនឹងហែលលុះដើរចុះទៅក្នុងទឹកឃើញទឹករាក់ក៏គក់ទ្រូងថា ឱ!អញស្មានតែជ្រៅលុះឆ្លងដល់ត្រើយ ក៏រត់តាម ស្រែកថា: អាចោរកំណាចនាំភរិយាអញទៅណា ៗ ឯអាទីឃបិដ្ឋ ឆ្លើយថាឯងបានពីណាមក ស្រីនេះជាប្រពន្ធរបស់អញទេតើ ថាហើយក៏ចាប់ក្បាលអាគោត្រកាលច្រានចេញទៅ ឯអាគោត្រកាលខឹងណាស់ក៏មកវិញ ម្នីម្នាចាប់ដៃនាង

ទីឃាតាហល ហើយថានាងឈប់ នាងទៅឯណា ? អញធ្វើការបំរើមាតាបិតានាង៧ឆ្នាំ ទើបអញបាននាងជាភរិយា ម្ដេចនាងរត់ពោលអញដូច្នេះ? អាគោត្រកាលធ្វើជុំលោះប្រកែកជាមួយនឹងអាទីឃបិដ្ឋនោះ ហើយបណ្ដើរគ្នាទៅ ដល់សាលានៃព្រះពោធិសត្វជនទាំងឡាយរមិលមើលបុរសនោះប្រកែកគ្នា មហោសថអ្នកប្រាជ្ញសួរថា: អ្វីហ្នឹង? ជនទាំងឡាយទូលរឿងហេតុនោះហើយ ទើបទ្រង់ប្រើឲ្យហៅអ្នកទាំងពីរលុះមកដល់ហើយក៏ស្ដាប់ពាក្យសំដីទើបត្រាប់ថា អានេះជាចោរលួចអានេះជាប្ដី ទើបនិយាយថា: អ្នកទាំងពីរស្ដាប់បង្គាប់អញឬ ? បុរសទាំងពីរទូលថា អំម្ចាស់យើងនឹងស្ដាប់បង្គាប់ ៗ ទើបព្រះមហោសថឲ្យហៅទីឃបិដ្ឋមកមុនហើយទ្រង់សួរថា: អាឯងឈ្មោះអ្វី? ឆ្លើយថា: ខ្ញុំឈ្មោះទីឃបិដ្ឋ ៗ ចុះនាងនោះឈ្មោះអ្វី ? អាទីឃបិដ្ឋមិនទាន់ស្គាល់នាងនោះទេ ថែរទៅជាឆ្លើយឈ្មោះដទៃវិញ, ចុះឪពុកម្ដាយឯងឈ្មោះអី? ឆ្លើយតាមដំណើរទៅ ចុះឪពុកក្មេកម្ដាយក្មេកឈ្មោះអី, អានោះវាមិនទាន់ស្គាល់ ក៏បេះតែឆ្លើយឈ្មោះដទៃផ្ដេះផ្ដាសទៅ ព្រះពោធិសត្វឲ្យកត់ពាក្យនោះហើយឲ្យចេញទៅ ៗ ទ្រង់ឲ្យហៅអាគោត្រកាលចូលមកទៀត ហើយសួរដូចជាអាទីឃបិដ្ឋដែរ អាគោត្រកាលក៏ឆ្លើយតាមវាស្គាល់សព្វគ្រប់ លុះកត់រួចហើយ ព្រះមហោសថឲ្យអាគោត្រកាលចេញទៅ ហើយទ្រង់ឲ្យហៅនាងទីឃាតាហលមកសួរទៀត ៗ នាងនោះឆ្លើយដូចជាអាគោត្រកាលដែរ ៗ ឯព្រះមហោសថឲ្យយក

កំណត់ចាំងបីមកមើលឲ្យមហាជនទាំងឡាយស្តាប់ហើយទ្រង់សួរទៀតថា នៃអ្នកទាំងឡាយ ពាក្យនេះដូចជាអាទីយបិដ្ឋមែនឬ? ឬដូចពាក្យអាគោត្រគាល ទើបមហាជនទូលឡើងថា: បពិតមហោសថអ្នកប្រាជ្ញដ៏ចំរើន ពាក្យនានទីឃាតាហលនេះ ដូចពាក្យអាគោត្រគាល អាគោត្រគាលនេះជាប្តីនាងនេះពិត ចំណែកអាទីយបិដ្ឋមិនមែនប្តីទេ ។ ពេលនោះព្រះពោធិសត្វ សួរទៅអាទីយបិដ្ឋថា ប្រស្តែងជាចោរពិតមែនឬ? អាទីយបិដ្ឋិពាអាចលក្ខុកឆ្លើយតាមត្រង់ថា !! ខ្ញុំជាចោរពិតមែន ៗ ទើបព្រះមហោសថឲ្យរាយកុងពេលនោះយ៉ាងខ្លាំង ៗ អាគោត្រគាលក៏បានភរិយារបស់ខ្លួនដោយសួស្តី ដោយអំណាចបុណ្យព្រះពោធិសត្វ ក៏សរសើរបញ្ញាព្រះពោធិសត្វ ហើយនាំភរិយារបស់ខ្លួនទៅវិញ ៗ ទើបព្រះពោធិសត្វឲ្យទូន្មានដល់អាទីយបិដ្ឋថា នៃប្រស្តែងហេតុអ្វី? ប្រស្តែងកាន់អកុសលធម៌ដូច្នេះ គេធ្វើបាបជាតិនេះប៉ុណ្ណោះ ប្រស្តែងជាពីបាកខ្លួនប៉ុណ្ណោះ ចុះទំពាំទៅអានាគតជាតិ គេធ្វើបាបជាងនេះទៅទៀត តើរាយ៉ាងម៉េចទៅ? នៃ ប្រស្តែងចាប់តាំងពីថ្ងៃនេះទៅ ចូរកុំប្រព្រឹត្តធ្វើយ៉ាងនេះទៀត បើប្រស្តែងធ្វើយ៉ាងនេះទៀត មុខជាគេធ្វើបាបទៀតហើយ ៗ

មានសេចក្តីនិទានមួយទៀតថា: កាលនោះមានបុរសម្នាក់ ជិះរទេះបរទៅស្រះ ដើម្បីនឹងដួតទឹកមុខមាត់ឲ្យស្អាតខ្លួន ក្បីណានោះព្រះឥន្ទ្រាធិរាជរមិលមើលដោយទិព្វចក្ខុ ឃើញព្រះពោធិសត្វ ព្រះឥន្ទ្ររំពឹងគិតថា

អញនឹងធ្វើពន្ធកនៃព្រះពុទ្ធនេះ ឲ្យស្ដេចប្រាកដនូវអានុភាពនៃប្រាជ្ញាពោធិសត្វ ព្រះឥន្ទ្រាធិរាជគិតដូច្នោះហើយ ក៏ចុះចាកសួគ៌ា មកកាសខ្លួនធ្វើជាបុរសម្នាក់ដើរមកជិតរទេះនៃបុរសនោះ បុរសបររទេះឃើញហើយក៏សួរថា: ប្រស្ដែងអ្នកទៅណា? ដើម្បីអ្វី? ព្រះឥន្ទ្រ ក៏ឆ្លើយថា: ខ្ញុំមកដើម្បីបម្រើប្រស្ដែង ។

បុរសនោះស្ដាប់ពាក្យនោះហើយ ក៏ចុះអំពីរទេះដើរនៅព្រៃទៅបំណាក ព្រះឥន្ទ្រាធិរាជឃើញបុរសនោះចុះដើរទៅក្នុងព្រៃដូច្នោះ ក៏ឡើងរទេះបរទៅ ឯបុរសជាម្ចាស់រទេះមកពីព្រៃវិញ ឃើញគេបររទេះខ្លួនទៅដូច្នោះក៏រត់តាម ជិតហើយស្រែកថានែ ! ប្រស្ដែងឈប់សិន បររទេះអញទៅណា? ព្រះឥន្ទ្រាធិរាជ ឆ្លើយវិញថា: ឯណារទេះប្រស្ដែង គេដទៃគ្មានរទេះដូចប្រស្ដែង ស្មានតែមានម្នាក់ឯងឬ? ភ្លីភ្លើ! រទេះនេះរទេះអញទេ ព្រះឥន្ទ្រថាដូច្នេះ បុរសនោះឈ្លោះនឹងព្រះឥន្ទ្រ ដល់ដើរទៅដល់ជិតសាលានៃព្រះពោធិសត្វៗ ទ្រង់សួរថា: ពាក្យអ្វីដូច្នេះទើបឲ្យហៅអ្នកទាំងពីរនោះមក ព្រះអង្គស្គាល់ថាអ្នកនេះជាព្រះឥន្ទ្រ អ្នកនេះជាម្ចាស់រទេះ សូម្បីស្គាល់ដូច្នោះក៏ដោយ ព្រះអង្គនៅតែពិចារណាហេតុនោះទៀត ទើបព្រះអង្គសួរអ្នកទាំងពីរនោះថា នែអ្នក! អ្នកឯងស្ដាប់ពាក្យខ្ញុំ? បុរសទាំងពីរនោះក៏ព្រមទទួលចាំស្ដាប់ ទើបព្រះពោធិសត្វបង្គាប់ថា: ឲ្យបុរសដទៃឡើងរទេះនេះបរទៅ ប្រស្ដែងទាំងពីរនាក់ចូររត់ទៅតាមក្រោយរទេះ បើបុរសណាមួយជាម្ចាស់រទេះ បុរសនោះមិនបោះបង់

ពោលរទេះរបស់ខ្លួនឡើយ អ្នកណាមិនមែនជាម្ចាស់រទេះអ្នកនោះមុខជានឹង បស់បង់ពោលថាតែប៉ុណ្ណោះហើយក៏ប្រើពលរបស់ព្រះអង្គឲ្យឡើងបររទេះ នោះទៅ ឯបុរសទាំងពីរនាក់នោះក៏កាន់កន្ទៃ្យរទេះរត់តាមក្រោយទៅ ឯ ម្ចាស់រទេះរត់ទៅបានបន្តិចក៏លែងរទេះចោល ព្រះឥន្ទ្រាធិរាជក៏រត់បន្តិច ៗ ទៅមួយអន្លើទឹងរទេះនោះ ព្រះពោធិសត្វប្រាប់អស់មហាជនទាំងឡាយថា: បុរសទៅតាមរទេះបានបន្តិចហើយឈរនៅស្ងៀមនោះជាម្ចាស់រទេះ ឯបុ-រសទៅហ្នឹងរទេះជាប់មិនឈប់នោះមិនមែនជាម្ចាស់រទេះទេ បុរសនោះជា ព្រះឥន្ទ្រាធិរាជ ( ជាស្តេចនៃទេវតា ) បានជាថាដូច្នេះពីព្រោះគាត់នេះមិន មានខ្លាប ១, ភ្នែកមិនប៉ប្រិច ១, ម្ចាស់រទេះឮហើយក៏សួរទៅថា: អ្នកជា ព្រះឥន្ទមែនឬ, ស្រាប់តែឆ្លើយវិញថាអើអញជាព្រះឥន្ទ្រគ្រាន់តែឮពាក្យ ថាព្រះឥន្ទដូច្នោះ ព្រះមហោសថសួរទៀតថា ចុះក៏អ្នកមកធ្វើអំពើយ៉ាងនេះ ព្រះឥន្ទ្រឆ្លើយថាហៃចៅអ្នកប្រាជ្ញ យើងមកនេះប្រយោជន៍ដើម្បីនឹងជួយ បញ្ញារបស់អ្នកឲ្យជាក់ច្បាស់, ព្រះឥន្ទ្រថាដូច្នេះក៏សម្តែងអានុភាពនៃខ្លួនជា ព្រះឥន្ទ្រទៅស្ថិតនៅចំពាក់កណ្តាលនៃអាកាស មានរស្មីបំភ្លឺដូចជាព្រះអាទិត ពេញវង្ស ទ្រង់សរសើរពោធិសត្វសព្វគ្រប់ហើយក៏ហោះទៅកាន់ទីកន្លែង របស់ខ្លួនវិញទៅ ។ ចំណែកអាមាត្យដែលព្រះរាជាប្រាប់ឲ្យឃ្លាំចាំស្តាប់ ការនៃចៅអ្នកប្រាជ្ញ ក៏នាំរឿងហេតុនោះទូលដល់ព្រះរាជាសព្វគ្រប់ ។ ស្តេចក៏សួរអាចារ្យសេនកថា ម្នាលលោកអាចារ្យ យើងឲ្យទៅនាំចៅ



អ្នកប្រាជ្ញនោះមកឬ? ឬដូចម្ដេច? អាចារ្យសេនក ឆ្លើយវិញថា៖ បពិត្រព្រះរាជា អ្នកមានចំណេះតែប៉ុណ្ណោះក៏មិនទាន់ហៅថាអ្នកប្រាជ្ញបានឡើយ សូមអម្ចាស់ឈប់ស្ងេះសិនចុះ យើងនឹងល្បងប្រាជ្ញាឲ្យអស់ចិត្តសិន ព្រះបាទវិទេហរាជស្ដាប់ហើយ ក៏នៅស្ងៀម ។

ម្យ៉ាងទៀតមានសេចក្ដីដំណាលថា: មានសម័យថ្ងៃមួយព្រះមហាក្សត្រាធិរាជមកជំនុំគារវៈគិតជាមួយនឹងអ្នកប្រាជ្ញទាំង៤ ដើម្បីល្បងមើលប្រាជ្ញានៃព្រះមហោសថ ស្ដេចឲ្យយកឈើគគីរ១ កំណាត់ប្រវែង ១ បំអាម ហើយឲ្យយកទៅធាងក្រឡឹងឲ្យស្មើរ ធ្វើមិនឲ្យដឹងខាងណាគល់ខាងណាចុង ហើយឲ្យអាមាត្យយកទៅឲ្យសិរីវឌ្ឍសេដ្ឋីថា ត្បិតស្ដេចមានព្រះបន្ទូលឲ្យយកមកផល់អ្នកឯង ឲ្យទាយកំណាត់គគីរនេះ ឲ្យដឹងខាងណាចុងខាងណាគល់ ថាបើដឹង អើកជាការឥតទោស បើមិនដឹងព្រះអង្គនឹងឲ្យអ្នកឯងមានទោសជាទម្ងន់ ឯសិរីវឌ្ឍសេដ្ឋីនឹងមហាជនស្រុកនោះ មកជំនុំពិចារណានឹងគ្នា ក៏ពុំដឹងកំណាត់គគីរនោះថា: ខាងណាចុងខាងណាគល់ឡើយ ទើបសិរីវឌ្ឍសេដ្ឋីគាត់ឲ្យទៅហៅព្រះមហោសថមកអំពីសាលាសម្រាប់លេងល្បែងនោះមកសួរថា: ម្នាលបាសំឡាញ់ខ្ញុំ! ឥឡូវនេះព្រះរាជាឲ្យយកកំណាត់គគីរមកឲ្យខ្ញុំនឹងមហាជនទាំងឡាយទាយ តើខាងណាចុងខាងណាគល់ យើងទាំងអស់គ្នាពុំអាចដឹងទេ, តែកូនបាមានប្រាជ្ញាអាចដឹងបានឬ? ព្រះមហោសថអ្នកប្រាជ្ញស្ដាប់ហើយទ្រង់ព្រះចិន្ដាពិចារណាហើយ ក៏លើកកំណាត់គគីរនោះកាន់ក្បាល គ្រាន់តែកាន់ ១ រំពេចប៉ុណ្ណោះឯង ក៏អាចដឹងបានថាខាងនេះចុងខាងនេះគល់ ព្រះពោធិសត្វទុកជាដឹងដូច្នោះហើយក៏ធ្វើជាមិនដឹង ប្រយោជន៍នឹងចង់ឲ្យមហាជនទាំងឡាយដឹងផង ទើបព្រះពោធិសត្វប្រើឲ្យយកភាជនៈមាស ១ ដាក់ទឹក ហើយឲ្យយកខ្សែអំ

ហោះមកចងពាក់កណ្ដាលកំណាត់គគីរនោះ ហើយលើកដាក់ក្នុងភាជនៈ កាន់ចុងខ្សែបណ្ដែត ខាងគល់ធ្ងន់ក៏លិចចុះក្នុងភាជនៈ ខាងចុងក៏អណ្ដែតឡើង ពេលនោះព្រះមហោសថ សួរទៅមហាជនទាំងឡាយថាៈ អ្នកទាំងឡាយ ឈើនេះធ្ងន់ខាងគល់ឬ? ឬធ្ងន់ខាងចុង? មហាជនឆ្លើយថាៈ បពិត្រព្រះមហោសថ! ឈើទាំងឡាយធ្ងន់ខាងគល់ទាំងអស់, ទើបព្រះមហោសថអ្នកប្រាជ្ញថាៈ ម្នាលអ្នកទាំងឡាយបើដូច្នោះខាងលិចនេះខាងគល់ ទើបព្រះពោធិសត្វឲ្យគូសចំណាំគល់នឹងចុងស្រេចហើយ ឲ្យនាំទៅថ្វាយព្រះមហាក្សត្រាធិរាជវិញ ។ ព្រះមហាក្សត្រាធិរាជស្ដេចជ្រាបហេតុនោះហើយក៏មានព្រះទ័យត្រេកអរជាពន់ពេក! មានព្រះបន្ទូលថាអ្នកណា អាចដឹងជាចុងជាគល់បាន? អស់មហាជនទាំងឡាយក្រាបបង្គំទូលថាៈ សូមទានចៅមហោសថ ជាបុត្ររបស់សិរីវឌ្ឍសេដ្ឋីដឹងថាខាងនេះចុងខាងនេះគល់ ព្រះមហាក្សត្រាធិរាជទ្រង់ព្រះសណ្ដាប់ហើយ មានព្រះបន្ទូលសួរទៅកាន់អាចារ្យសេនកថា តើយើងល្មមឲ្យទៅនាំមហោសថមកទុកជាអ្នកប្រាជ្ញឬ! ឬដូចម្ដេច? អាចារ្យសេនកទូលទាស់ទៀតថាៈ បពិត្រមហារាជសូមទានឈប់សិន ចាំទូលព្រះបង្គំនឹងល្បងដោយនៅឧបាយកលឲ្យអស់ចិត្តសិន ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយ មានព្រះបន្ទូលថាអ្នកឯងគិតនេះគាប់ហើយ ។

ម្យ៉ាងទៀតមានសេចក្ដីដំណាលថាៈ សម័យថ្ងៃមួយអាចារ្យទាំង ៤ នាក់ ជំនុំគ្នារិះគិតឲ្យស្ដេចល្បងមើល... ឲ្យទៅយកក្បាលខ្មោចទាំងពីរ

គឺក្បាលខ្មោចស្រី ១ ក្បាលខ្មោចប្រុស ១ ឲ្យយកទៅកាន់កន្លែងសិរីវឌ្ឍ សេដ្ឋី ទឹងអស់អ្នកស្រុក, ថាដ្បិតមានព្រះបន្ទូល ត្រាស់ឲ្យយក ក្បាលខ្មោចទាំងពីរមកឲ្យអ្នកទាយ តើខ្មោចណាប្រុស ខ្មោចណាស្រី ថាបើអ្នកទាយត្រូវក៏ជាការឥតទោស, សិរីវឌ្ឍសេដ្ឋី សួរទៅមហោសថ ទៀត មហោសថអ្នកប្រាជ្ញព្រះអង្គរមិលមើលហើយ ព្រះពោធិសត្វ ស្គាល់១រំពេចថាក្បាលនេះប្រុស ក្បាលនេះស្រី ពីព្រោះក្បាលខ្មោចប្រុស មានសរស្រែកនោះវែងក្រឡាប់ទិចហើយគេចវិញ ទើបព្រះមហោសថ ប្រាប់ទៅមហាជនទាំងឡាយនោះថា: នេះពិតជាក្បាលខ្មោចប្រុស នេះ ក្បាលខ្មោចស្រី, ទើបសិរីវឌ្ឍសេដ្ឋី យកទៅថ្វាយព្រះរាជាវិញ ស្ដេច ទ្រង់ជ្រាបហេតុនោះសព្វគ្រប់ហើយ ក៏មានព្រះហឫទ័យសោមនស្ស ត្រេកអរជាពន់ពេក ៗ ទើបព្រះមហាក្សត្រាធិរាជមានព្រះបន្ទូលទៅ អាចារ្យទាំង ៤ ថា ឥឡូវនេះព្រះមហោសថទាយត្រូវទៀតហើយ តើ យើងគិតដូចម្ដេច ។

## នៅមានតទៅខ្សែទី ២ ទៀត

ខ្សែ ២ ដើមស្ដេចឲ្យមហោសថដល់ប្រស្នា ៩ ១ មានឲ្យរកគោរដុស ស្នែងទឹងជើង ប៊ីរនៅពីលើ ទឹងឲ្យយកដីខ្សាច់ទៅវិញធ្វើជាតួរជាដើម កណ្ដាលសួរអំពីក្សត្រីគ្រប់លក្ខ ហើយរូបល្អយ៉ាងឆើតបានប្ដីប្រុសសា-មញ្ញ តែប្ដីនោះមិនព្រមរួមសន្និវាសជុំមហោសថជួបទឹងនាងអមរាដស ប្រស្នាគ្នា ៩ ហើយយល់ចិត្តនាងអមរា ៣ យ៉ាង ។

# សៀវភៅដែលមានជារនៅគេហស្ថាន គឹម.គី គី:

| | | |
|---|---|---|
| ច្បាប់បរទ្យាន . . . . | ១ សៀវភៅថ្លៃ | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ . | ,, | ៨៛០០ |
| តេជាដំរិន ទី ១ ដល់ទី ៧ ចប់ . . | ,, | ៨៛០០ |
| ទឹកកំផ្កាកំ ទី ១ ទី ២ ចប់ . . . | ,, | ៨៛០០ |
| កាព្យកំសាន្តចិត្ត . . . . | ,, | ៦៛០០ |
| រឿងធន្ទមឿង ទី ១ ទី ២ ចប់ . . | ,, | ៨៛០០ |
| រឿងធនញ្ជ័យ . . . . | ,, | ១២៛០០ |
| រឿងអាឡាជាំងមនុស្សមាត់ទិព្វបង្កៀនទិព្វ | ,, | ១៤៛០០ |
| រឿងព្រះសធន នាងកែវមនោរា ទី ១ ទី ២ ចប់ | ,, | ៩៛០០ |
| រឿងសូផាត . . . . | ,, | ១០៛០០ |
| ភិម្ពាពិលាប . . . . | ,, | ១០៛០០ |
| នានាធម្មសំវេគ . . . . | ,, | ៨៛០០ |
| ល្បើកសត្វអក . . . . | ,, | ៤៛០០ |
| កុមារដ្ឋាន . . . . . | ,, | ១០៛០០ |
| រឿងតាវឯក ទី ១ ទី ២ ទី ៣ ទី ៤ . | ,, | ៤៛០០ |
| សេកសារិកា . . . . | ,, | ៧៛០០ |
| រឿងរតនាវង្ស ទី ៦ ទី ៧ ទី ៨ . . | ,, | ៥៛០០ |
| សុន្ទរកថា . . . . . | ,, | ៥៛០០ |
| ទេវតាភាសិត . . . . | ,, | ៥៛០០ |

# សៀវភៅដែលមានជាវនៅគេហស្ថាន គឹម-គី គឹះ

| | | |
|---|---|---|
| បកិណ្ណកបរិត . . . . | ១សៀវភៅថ្លៃ | ១២៛០០ |
| វេយ្យាករណ៍បាឋទី ១ . . . | ” | ១៨៛០០ |
| ” ” ទី ២ . . . . | ” | ១៧៛០០ |
| វេយ្យាករណ៍ខ្មែរ . . . . | ” | ១៣៛០០ |
| លេខទៀវ . . . . | ” | ១៥៛០០ |
| ធម្មសង្គហៈ ភាគ ១ ភាគ ២ . . | ” | ១៥៛០០ |
| បញ្ញានិទ្ទេស . . . . | ” | ២៥៛០០ |
| ប្រស្នាគិហិបដិបត្តិ . . . . | ” | ១៨៛០០ |
| វិធីប្រែបាលី . . . . | ” | ២៥៛០០ |
| ប្រស្នាអភិធម្ម . . . . | ” | ២៥៛០០ |
| ប្រស្នាត្រៃគុណ . . . . | ” | ២៥៛០០ |
| សាមណេរវិន័យបញ្ហា . . . | ” | ២០៛០០ |
| រឿងព្រះមហោសថ | | ១០៛០០ |

## សៀវភៅកំពុងបោះពុម្ពតទៅ

រឿងដំបងក្រញូង - ភ្នំក្រក - បក្សីចាំក្រុង

| | |
|---|---|
| រឿងនាងពីដណ្ដប់ | រឿងចម្ប៉ាថោងពិញ្ចាមក្រពើ |
| រឿងព្រះថោងនាងនាគ | រឿងព្រះបាទអជាតសត្រូវ |
| រឿងព្រះបរគោរព | រឿងជ័យសូរវង្ស |
| រឿងទិពទេវទត្ត | រឿងព្រះសុវណ្ណវង្ស |

នឹងសៀវភៅ បាលី ខ្មែរ ដទៃទៀតជាច្រើន

ការផ្សាយរបស់

លេខ ៨៨ វិថីអេមេគ្រន៍ ភ្នំពេញ
ដិតពោធ៍គុនព្រហ្មាយ៉នផ្ទាល់

រក្សាសិទ្ធិ

រោងពុម្ពអាស្ប៉ាទិជ
ភ្នំពេញ

ថ្លៃ ១០៛០០